# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

០៩-០១-២០១៤ -ព្រះរាជក្រម នស/រកម/០១១៤/001 ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើពិធីសារ និងពិធីសារទី ២ ដើម្បីវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ៤៨៧

### ២~ព្រះរាជក្រឹត្យ

២១-១២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៣ ស្តីពី ការបញ្ចប់តំណែងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ និងត្រូវបាន កែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១៨ រូប ៥១៧

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៤ ស្តីពី ការបញ្ចប់តំណែងអនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ និងត្រូវបានតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១១ រូប ៥១៩

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៥ ស្តីពី ការតែងតាំងឯកឧត្តម **យី ផន** ជានាយករង ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជា ណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ៥២១

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៦ ស្តីពី ការតែងតាំងលោកជំទាវ **ស៊ិន សេរី** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី ៥២២

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៧ ស្តីពី ការតែងតាំងឯកឧត្តម **ហោ ណាំបូរ៉ា** ជាអគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ ៥២៣

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៨ ស្តីពី ការតែងតាំងឯកឧត្តម **តើត សេតារឿ** ជាអគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម **សួរ ចាន់ធី** ដែលត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និង តែងតាំងឯកឧត្តម **ប៊ុនឈៃ ណារិន** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន នៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ មានឋានៈស្មើ អគ្គនាយក ជំនួសឯកឧត្តម **តើត សេតារឿ** ៥២៤

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៩ ស្ដីពី ការតម្លើងឋានន្តរស័ក្ដិថ្នាក់ឧត្ដមសេនីយ៍ទោ ជូនលោកឧត្ដមសេនីយ៍ត្រី **ច័ន្ទ សុខណ្ណ** នាយនគរបាលថ្នាក់ឧត្ដមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥២៥

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០០ ស្ដីពី ការតែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ៥២៦

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០១ ស្ដីពី ការផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល ៥២៧

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០២ ស្ដីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និង សមាសភាពនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ចំនួន ០៧ រូប ៥២៩

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០៣ ស្ដីពី ការតែងតាំង និងតម្លើងឋានន្តរស័ក្ដិឯកឧត្ដម ស **សាម៉ុឌី** ជាទីប្រឹក្សាក្រសួងមុខងារសាធារណៈ មានឋានៈស្មើអគ្គនាយក ៥៣១

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០៤ ស្ដីពី ការតែងតាំងឯកឧត្ដម **ផេង សុខាំ** ជាអនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងតែងតាំងមន្ត្រីរាជការចំនួន ០៩ រូប ជាទីប្រឹក្សាអម ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ៥៣២

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០៥ ស្ដីពី ការតែងតាំងមន្ត្រីរាជការ ចំនួន ០៩ រូប ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងតែងតាំងអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយចំនួន ០៣ រូប ៥៣៣

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០៦ ស្ដីពី ការតែងតាំងជំនួយការឯកឧត្ដម **ញឹម ខណ្ឌជា** ចំនួន ០២ រូប និង ជំនួយការឯកឧត្ដម **លី ធុច** ចំនួន ០២ រូប ៥៣៥

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ចំនួន ០៤ រូប ៥៣៦

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ អស់លោក ចំនួន ០៣ រូប ៥៣៧

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤០៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ព្រះសង្ឃ និងអស់លោក ចំនួន ០៣ រូប/អង្គ ៥៣៨

២៣-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះកងកម្លាំងប្រដាប់អាវុធ ចំនួន ១០៤ រូប ៥៣៩

២៦-១២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១០ ស្តីពី ការផ្ទេរ និងតែងតាំង ឯកឧត្តម **កេ គិមស៊ែ** ពីនាយកព្រះរាជខុទ្ទកាល័យ **ព្រះមហាវីរក្សត្រ** ព្រះវររាជបិតាជាតិខ្មែរ ជានាយក ព្រះរាជខុទ្ទកាល័យ សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៥៤៤

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១១ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ឡៅ ស៊ាវគ** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥៤៥

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះកងកម្លាំងប្រដាប់អាវុធ ចំនួន ០៧ រូប ៥៤៦


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


៣១.១២.២០១៣ -អនុក្រឹត្យលេខ ៥៩៣ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៥០៨,២៩ ហិកតា នៅសង្កាត់ច្បារមន និងសង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីចំការដាំឈើភ្នំក្រាយ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១១៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៤៧

៣១.១២.២០១៣ -អនុក្រឹត្យលេខ ៥៩៤ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៧៣០,៨២ ហិកតា នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.០៣៩ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៦៣

០៦-០១-២០១៤ -អនុក្រឹត្យលេខ ១២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាន់ខ្ពស់ ៥៧៣

០៦-០១-២០១៤ -អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៧៥

០៦-០១-២០១៤ -អនុក្រឹត្យលេខ ១៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៧៦

០៦-០១-២០១៤ -អនុក្រឹត្យលេខ ១៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៧

០៨-០១-២០១៤ -អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៥៧៩

០៨-០១-២០១៤ -អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ ៥៨២
០៨-០១-២០១៤ -អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៥៨៥

## ២. សេចក្តីសម្រេច

០៨-០១-២០១៤ -សេចក្តីសម្រេចលេខ ០៣ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥៨៧
០៩-០១-២០១៤ -សេចក្តីសម្រេចលេខ ០៤ សសរ ស្តីពី ការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ៥៨៩

## III. ការងារបណ្តាក្រសួង

## ទីស្តីការក្រសួងមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១១-១២-២០១៣-ប្រកាសលេខ ១៣៣០ សហវ.ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ៥៩១

# ព្រះរាជក្រម

នស/រកម/០១១៤/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារ និងពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការ សេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើពិធីសារ និងពិធីសារទី២ ដើម្បីធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្រប ខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោម ប្រទេសសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារ និងពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ដែលបានចុះហត្ថលេខានៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ នាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ និងនៅទីក្រុងបាលីសាធារណរដ្ឋឥណ្ឌូនេស៊ី នាថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារ និងពិធីសារទី២ នេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤

ចរកម. ១៤០១.០២៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខៈ ៤០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៥៧. សព្រ**

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៨ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងក្របខ័ណ្ឌសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន - កូរ៉េ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាលកម្ពុជា

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ដើម្បីចុះហត្ថលេខា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លើពិធីសារទីពីរ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ក្នុងចំណោមប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ។

ក្នុងករណីឯកឧត្តម **ចម ប្រសិទ្ធ** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

អាស្រ័យហេតុនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចដែលច្បាប់បានប្រគល់ជូន បានចុះ ហត្ថលេខាលើសិទ្ធិប្រទាននេះ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ពិធីសារទីពីរ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ**

រដ្ឋាភិបាលនៃប្រ៊ុយណេដារ៉ូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បណ្តាប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ជារួមហៅថា "អាស៊ាន" ឬ "បណ្តាប្រទេសសមាជិកអាស៊ាន" ឬ ដោយឡែក " ប្រទេសសមាជិកអាស៊ាន" ) និងសាធារណរដ្ឋកូរ៉េ (ហៅថា "កូរ៉េ") (ដោយឡែក ហៅថា "ភាគី" និងជារួមហៅថា "បណ្តាភាគី")។

**ដោយនឹកឃើញ** កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ (ហៅថា "កិច្ចព្រមព្រៀង") បានចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦។

**ដោយទទួលស្គាល់ថា** គ្មានអ្វីក្នុងកិច្ចព្រមព្រៀងនេះរារាំងបណ្តាភាគីពីការពន្លឿន និង/ឬ ការធ្វើឲ្យប្រសើរឡើងជាឯកតោភាគីនូវការសន្យាពន្ធ ដែលបានធ្វើឡើងក្នុងកិច្ចព្រមព្រៀង។

**ដោយប្រាថ្នា** បញ្ជាក់ឲ្យបានច្បាស់បទប្បញ្ញត្តិនានាទាក់ទងទៅនឹងការពន្លឿននៃការអនុវត្តសម្បទាន និងការបញ្ចូលទំនិញថ្មីទៅក្នុងសម្បទាននោះ ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ៦ នៃកិច្ចព្រមព្រៀង ការពន្លឿនជាឯកតោភាគីនៃការកាត់បន្ថយ ឬការលុបបំបាត់ពន្ធ ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀង និងការពន្លឿនជាឯកតោភាគីនៃការបន្ថយ និង/ឬ ការលុបបំបាត់ពន្ធនៃបន្ទាត់ពន្ធបានដាក់ក្នុងកម្មវិធីវេទយិត និងការផ្ទេរជាឯកតោភាគីនៃបន្ទាត់ពន្ធពីកម្មវិធីវេទយិតទៅក្នុងកម្មវិធីធម្មតា យោងទៅតាមកថាខ័ណ្ឌ ៦ នៃឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀង។

**ដោយស្វះស្វែង** បង្កើតល័ក្ខខ័ណ្ឌសម្រាប់ពន្លឿននៃការកាត់បន្ថយ និង/ឬ ការលុបបំបាត់ពន្ធសម្រាប់បន្ទាត់ពន្ធបានដាក់នៅក្នុងកម្មវិធីធម្មតា និងកម្មវិធីវេទយិត និងត្រៀមសម្រាប់ការសម្របសម្រួល

ដែលត្រូវបញ្ចូលជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង។

**ដោយកត់សម្គាល់ថា** មាត្រា ១៧ នៃកិច្ចព្រមព្រៀងចែងថាការកែប្រែណាមួយពាក់ព័ន្ធដល់មាត្រានោះ ត្រូវមានការព្រមព្រៀងគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយបណ្តាភាគី។

*បានព្រមព្រៀងដូចតទៅ៖*

## មាត្រា ១

## វិសោធនកម្មដើម្បីបញ្ចូលមាត្រា ៦ ថ្មីស្ទួន ទៅក្នុងកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងត្រូវធ្វើវិសោធនកម្មដោយបញ្ចូលមាត្រា ៦ ថ្មីស្ទួន ភ្លាមបន្ទាប់ពីមាត្រា ៦ នៃកិច្ចព្រមព្រៀងដូចតទៅ៖

## មាត្រា ៦ ស្ទួន

## ការពន្លឿន នៃការសន្យាពន្ធ

១. ដើម្បីគោលបំណងនៃមាត្រានេះ ការពន្លឿន និង/ឬ ការធ្វើឲ្យប្រសើរឡើងនៃការសន្យាពន្ធ អាចបញ្ចូលបន្ថែមទំនិញថ្មីទៅក្នុងការសន្យាពន្ធដែលបានធ្វើនៅក្រោមកិច្ចព្រមព្រៀងនេះ។

២. (ក) ភាគីអាចពន្លឿនជាឯកតោភាគីនូវការកាត់បន្ថយ និង/ឬ ការលុបបំបាត់នៃពន្ធលើទំនិញមានប្រភពដើមរបស់ភាគីឯទៀត នៅពេលណាមួយ ប្រសិនបើខ្លួនមានបំណងធ្វើដូចនេះ ដូចមានចែងក្នុងថាខ័ណ្ឌ ២ នៃឧបសម្ព័ន្ធ ១ ឬកថាខ័ណ្ឌ ៦ នៃឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀង។ សម្បទានពន្ធកើតពីការពន្លឿន និង/ឬ ការលុបបំបាត់ពន្ធត្រូវផ្តល់ទៅដល់ភាគីទាំងអស់។

(ខ) ដូចគ្នាផងដែរ ភាគីណាក៏ដោយអាចផ្ទេរជាឯកតោភាគីនូវបន្ទាត់ពន្ធណាមួយពីកម្មវិធីវេទយិតទៅកម្មវិធីធម្មតា នៅពេលណាមួយ ប្រសិនបើគេមានបំណងដូចនេះ ដូចមានចែងក្នុងកថាខ័ណ្ឌ ៦ នៃឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀង។ សម្បទានពន្ធពីការធ្វើឲ្យប្រសើរឡើងនៃការសន្យាពន្ធត្រូវផ្តល់ទៅដល់ភាគីទាំងអស់។

៣. ដូចគ្នាផងដែរ ភាគីពីរ ឬច្រើនជាងនេះ អាចចរចា និងចុះហត្ថលេខាលើកិច្ចសម្របសម្រួលដើម្បីពន្លឿន និង/ឬ ធ្វើឲ្យប្រសើរឡើងនូវការសន្យាពន្ធនៅក្នុងកម្មវិធី នៃការសន្យាពន្ធរបស់ពួកគេដែលបានធ្វើឡើងក្រោមកិច្ចព្រមព្រៀងនេះ ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ៦ នៃកិច្ចព្រមព្រៀង។ សម្បទានពន្ធកើតពីការពន្លឿន និង/ឬ ការធ្វើឲ្យប្រសើរឡើងនៃការសន្យាពន្ធត្រូវផ្តល់ទៅឲ្យភាគីទាំងអស់។

៤. គ្មានអ្វីក្នុងកិច្ចព្រមព្រៀងរារាំងភាគីទាំងអស់ពីការចរចា និងចុះហត្ថលេខាលើកិច្ចសម្រប សម្រួលដើម្បីពន្លឿន និង/ឬ ការធ្វើឲ្យប្រសើរឡើងនូវការសន្យាពន្ធដែលបានធ្វើឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ៦ នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ២
## ការធ្វើវិសោធនកម្មនៃមាត្រា ១៧ នៃកិច្ចព្រមព្រៀង

មាត្រា ១៧ នៃកិច្ចព្រមព្រៀងត្រូវធ្វើវិសោធនកម្ម និងជំនួសដោយមាត្រា ១៧ ថ្មី មានដូចខាងក្រោម៖

## "មាត្រា ១៧
## វិសោធនកម្ម

១. បទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះអាចកែប្រែតាមរយៈការធ្វើវិសោធនកម្ម ដោយការព្រមព្រៀងគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយភាគីទាំងអស់។

២. ភាគីនីមួយៗត្រូវជូនដំណឹងទៅភាគីឯទៀត ជាលាយលក្ខណ៍អក្សរថា នីតិវិធីផ្ទៃក្នុងចាំបាច់សម្រាប់ចូលជាធរមាននៃវិសោធនកម្មបានបញ្ចប់។ វិសោធនកម្មនោះត្រូវចូលជាធរមាននៅថ្ងៃទី ១ នៃខែទី ២ បន្ទាប់ពីកាលបរិច្ឆេទដែលការជូនដំណឹងនោះបានធ្វើឡើងដោយភាគីកូរ៉េ និងប្រទេសសមាជិកអាស៊ានមួយយ៉ាងតិច ទាក់ទងដល់ភាគី ដែលបានធ្វើការជូនដំណឹងនៅកាលបរិច្ឆេទនោះ។

៣. ក្នុងករណី ដែលប្រទេសសមាជិកណាមួយនៃប្រទេសសមាជិកអាស៊ានដែលនៅមិនទាន់បានជូនដំណឹង ដូចមានចែងក្នុងកថាខ័ណ្ឌ ២ ក្រោយកាលបរិច្ឆេទដែលការជូនដំណឹងបានធ្វើឡើងដោយភាគីកូរ៉េ និងប្រទេសសមាជិកអាស៊ានមួយយ៉ាងតិច ដូចមានចែងក្នុងកថាខ័ណ្ឌ ២ វិសោធនកម្មតាមកថាខ័ណ្ឌ ១ ត្រូវចូលជាធរមានចំពោះប្រទេសសមាជិកអាស៊ាននោះនៅថ្ងៃទី១ នៃខែទី ២ ក្រោយកាលបរិច្ឆេទនៃការជូនដំណឹង។

៤. ថ្វីបើមានកថាខ័ណ្ឌ ២ និង ៣ ចំនួនប្រទេសសមាជិកអាស៊ាន ដូចមានចែងក្នុងកថាខ័ណ្ឌ ២ ដែលតម្រូវជាអប្បបរមាសម្រាប់ការចូលជាធរមាននៃវិសោធនកម្ម អាចបង្កើនតាមការព្រមព្រៀងក្នុងចំណោមភាគីទាំងអស់។

*Unofficial Translation*
*Department of Economic Integration and ASEAN*
*Ministry of Economy and Finance*

៥. ថ្វីបើមានកថាខណ្ឌ ១ ដល់ ៤[1]

(ក) ចំពោះវិសោធនកម្មដែលបានធ្វើ ស្របតាមកថាខណ្ឌ ២(ក) នៃមាត្រា៦ ស្ទួន នៃកិច្ចព្រមព្រៀង ភាគីត្រូវជូនដំណឹងទៅភាគីទាំងអស់ឯទៀតតាមរយៈកំណត់ទូតជាបន្ទាន់ បន្ទាប់ពីបញ្ចប់នីតិវិធីផ្ទៃក្នុង តម្រូវសម្រាប់ការចូលជាធរមានវិសោធនកម្ម ។ វិសោធនកម្មនោះត្រូវចូលជាធរមានតាមកាលបរិច្ឆេទជាក់លាក់ដូចមាននៅក្នុងកំណត់ទូត ឬ ទោះយ៉ាងណាក៏ដោយ នៅក្នុងរយៈពេល ៩០ ថ្ងៃចាប់ពីការជូនដំណឹង។ សម្បទានណាមួយដែលបានផ្តល់ដោយភាគីស្របតាមការពន្លឿនជាឯកតោភាគី ដូចមានចែងនៅក្នុងវិសោធនកម្មនោះមិនត្រូវអនុញ្ញាតឲ្យដកចេញ។

(ខ) ចំពោះវិសោធនកម្មដែលបានធ្វើឡើងស្របតាមកថាខណ្ឌ ២(ខ) នៃមាត្រា៦ ស្ទួន នៃកិច្ចព្រមព្រៀង ភាគីត្រូវជូនដំណឹងដល់ភាគីទាំងអស់ឯទៀតៗជាកំណត់ទូតជាបន្ទាន់ បន្ទាប់ពីការបញ្ចប់នីតិវិធីផ្ទៃក្នុង ដែលតម្រូវសម្រាប់ការចូលជាធរមានវិសោធនកម្ម។ វិសោធនកម្មលើសេចក្តីបន្ថែមនានារបស់ឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀងត្រូវចូលជាធរមាននៅកាលបរិច្ឆេទជាក់លាក់ ដូចមានក្នុងកំណត់ទូត ឬ ទោះយ៉ាងណាក៏ដោយនៅក្នុងរយៈពេល ៩០ ថ្ងៃចាប់ពីការជូនដំណឹងនោះ។ នៅពេលភាគីណាមួយផ្ទេរជាឯកតោភាគីបន្ទាត់ពន្ធពីកម្មវិធីវេទយិតទៅកម្មវិធីធម្មតា ភាគីនោះមិនត្រូវផ្ទេរបន្ទាត់ពន្ធនោះត្រឡប់ទៅកម្មវិធីវេទយិតវិញ។ បណ្តាភាគីដែលបានទទួលព័ត៌មានពីការផ្ទេរជាឯកតោភាគីតាមរយៈកំណត់ទូតត្រូវបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីបញ្ឈប់ការអនុវត្តប្រព្រឹត្តកម្មពន្ធបដិការសម្រាប់បន្ទាត់ពន្ធដូចគ្នានោះ ប្រសិនបើមាន នៅក្នុងរយៈពេល ៩០ថ្ងៃចាប់ពីកាលបរិច្ឆេទ នៃការទទួលកំណត់ទូត និងជូនដំណឹងទៅភាគីទាំងអស់ឯទៀតនៅពេលបញ្ចប់នីតិវិធីផ្ទៃក្នុងតាមរយៈកំណត់ទូត។ នៅពេលភាគីមិនអាចបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួននៅក្នុងរយៈពេល ៩០ថ្ងៃ ដែលបានចែងនោះ ភាគីនោះត្រូវជូនដំណឹងដល់ភាគីទាំងអស់ឯទៀតតាមរយៈកំណត់ទូត ពីការមិនបានបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន។ ក្នុងករណីនេះ ការបន្ថែមរយៈពេល ៦០ថ្ងៃទៀត ត្រូវផ្តល់ដល់ភាគីនោះសម្រាប់ធ្វើសកម្មភាពនោះ ហើយភាគីនោះត្រូវជូនដំណឹងទៅដល់ភាគីទាំងអស់ឯទៀតតាមរយៈកំណត់ទូតជាបន្ទាន់ បន្ទាប់ពីបញ្ចប់នីតិវិធីផ្ទៃក្នុងសម្រាប់ការចូលជាធរមាននៃវិសោធនកម្ម។

---

[1] ក្នុងករណីប្រទេសឥណ្ឌូនេស៊ី ក្រៅពីកំណត់ទូត ដូចមានចែងក្នុងអនុកថាខណ្ឌ (ក) (ខ) និង (គ) ត្រូវមានលិខិតយោគយល់គ្នារវាងឥណ្ឌូនេស៊ី និងភាគីនោះ និងវិសោធនកម្មណាមួយបានធ្វើឡើងទៅលើសេចក្តីបន្ថែមនានា របស់ឧបសម្ព័ន្ធ ១ ២ និង ៣ និងឯកសារភ្ជាប់ពាក់ព័ន្ធ ត្រូវចូលជាធរមាននៅពេលការជូនដំណឹងនៃការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន។

(គ) ចំពោះវិសោធនកម្មដែលបានធ្វើស្របតាមកថាខ័ណ្ឌ ៣ នៃមាត្រា៦ ស្ទួន នៃកិច្ចព្រមព្រៀង ភាគីនីមួយៗដែលធ្វើវិសោធនកម្មនោះ ត្រូវជូនដំណឹងដល់ភាគីឯទៀត តាមរយៈកំណត់ទូតជាបន្ទាន់ បន្ទាប់ពីការបញ្ចប់នីតិវិធីផ្ទៃក្នុងសម្រាប់វិសោធនកម្មនោះចូលជាធរមាន។ វិសោធនកម្មនោះត្រូវចូលជាធរមានតាមកាលបរិច្ឆេទដែលបានចែងក្នុងកំណត់ទូត ឬនៅកាលបរិច្ឆេទឯទៀតដែលភាគីជាប់ពាក់ព័ន្ធទាំងអស់អាចព្រមព្រៀង។ សម្បទានណាមួយដែលបានផ្តល់ដោយបណ្តាភាគីទស្របតាមការពន្លឿនដូចមានចែងក្នុងកំណត់ទូតមិនត្រូវដកចេញបានទេ។

៦. ថ្វីបើមានកថាខ័ណ្ឌ ១ ដល់ ៥ ក៏ដោយ សេចក្តីបន្ថែមនានារបស់ឧបសម្ព័ន្ធ ៣ និង ឯកសារភ្ជាប់ពាក់ព័ន្ធនានា នៃកិច្ចព្រមព្រៀងអាចកែប្រែតាមការធ្វើវិសោធនកម្មដែលយល់ព្រមដោយគណៈកម្មាធិការអនុវត្ត។ វិសោធនកម្មនោះត្រូវចូលជាធរមាននៅកាលបរិច្ឆេទសម្រេចដោយគណៈកម្មាធិការអនុវត្ត។ គណៈកម្មាធិការអនុវត្តត្រូវរាយការណ៍ពីវិសោធនកម្មនោះជូនទៅរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន+កូរ៉េ។

## មាត្រា៣
## ការចូលជាធរមាន

១. ពិធីសារនេះគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀង។ ពិធីសារនេះត្រូវចូលជាធរមាន ៩០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទ ដែលភាគីកូរ៉េ និងប្រទេសសមាជិកអាស៊ានមួយយ៉ាងតិចបានជូនដំណឹងទៅភាគីទាំងអស់ឯទៀតជាលាយលក្ខណ៍អក្សរពីការបញ្ចប់នីតិវិធីផ្ទៃក្នុងចាំបាច់សម្រាប់ការចូលជាធរមាននៃពិធីសារនេះ។

២. ភាគីនីមួយៗ នៅពេលបំពេញនីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃពិធីសារនេះ ត្រូវជូនដំណឹងទៅភាគីទាំងអស់ឯទៀតជាលាយលក្ខណ៍អក្សរ។

៣. ក្នុងករណីដែលភាគីមិនអាចបញ្ចប់នីតិវិធីផ្ទៃក្នុងសម្រាប់ចូលជាធរមាននៃពិធីសារនោះតាមកាលបរិច្ឆេទនៃការចូលជាធរមានដូចមានចែងក្នុងកថាខ័ណ្ឌ ១ ពិធីសារនេះត្រូវចូលជាធរមានសម្រាប់ភាគីពាក់ព័ន្ធនោះ នៅកាលបរិច្ឆេទនៃការជូនដំណឹងពីការបញ្ចប់នីតិវិធីផ្ទៃក្នុងនោះ។

## មាត្រា ៤
## ការតម្កល់ទុក

សម្រាប់ប្រទេសសមាជិកអាស៊ាន ពិធីសារនេះត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវផ្តល់ជាបន្ទាន់នូវច្បាប់បញ្ជាក់ត្រឹមត្រូវទៅដល់ប្រទេសសមាជិកអាស៊ាននីមួយៗ។

*Unofficial Translation*
*Department of Economic Integration and ASEAN*
*Ministry of Economy and Finance*

*ជាសក្ខីភាព* ហត្ថលេខីខាងក្រោម ដែលបានអនុញ្ញាតត្រឹមត្រូវដោយរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី ២ នេះ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ។

*ធ្វើនៅក្រុងបាលី ឥណ្ឌូនេស៊ី នាថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចំនួនពីរច្បាប់ជាភាសាអង់គ្លេស។*

សម្រាប់រដ្ឋាភិបាលប្រ៊ុយណេឡូរូសាឡាំ សម្រាប់រដ្ឋាភិបាល សាធារណរដ្ឋកូរ៉េ

LIM Jock Seng
រដ្ឋមន្ត្រីទី២ ក្រសួងការបរទេសនិងពាណិជ្ជកម្ម

Kim Sung-Hwan
រដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្ម

សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

Cham Prasidh
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

Gita Wirjawan
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

*Unofficial Translation*
*Department of Economic Integration and ASEAN*
*Ministry of Economy and Finance*

Nam Viyaketh
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលម៉ាឡេស៊ី

Mustapa Mohamed
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

U Tin Naing Thein
រដ្ឋមន្ត្រីក្រសួងផែនការជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

Gregory L. Domingo
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសិង្ហបុរី

Lim Hng Kiang
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលព្រះរាជាណាចក្រថៃ
Kittiratt Na-Ranong
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

Vu Huy Hoang
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

រាជរដ្ឋាភិបាល
*Royal Government*

N: 157-D.F.P

Phnom Penh, November 15, 2011

**DELEGATION OF FULL POWER**

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Decree No. NS/RKT/0908/1055 dated 25 September 2008 on the Composition of the Royal Government of Kingdom of Cambodia;
- Having seen the Royal Decree No. 02/NS/94 dated 20 July 1994 on the Organization and the Functioning of the Council of Ministers;
- Having seen the Royal Decree No. NS/RKM/1207/034 dated 08 December 2007 promulgating the adoption of Framework Agreement on ASEAN-Korea Free Trade Area;
- Referring to the request of the Ministry of Economy and Finance.

**THE ROYAL GOVERNMENT OF CAMBODIA**

Delegates herewith full power to H.E. **CHAM PRASIDH**, Senior Minister, Minister of Commerce and Minister in charge of the ASEAN Economic Minister, to sign, on behalf of the Royal Government of Cambodia, the Second Protocol to amend the Agreement on Trade in Goods under the Framework Agreement on Comprehensive Economic Cooperation among the Governments of Member Countries of the Association of Southeast Asian Nations and the Republic of Korea.

This power includes the power of delegation.

In witness whereof, the undersigned, Samdech Akka Moha Sena Padei Techo **HUN SEN**, Prime Minister of the Kingdom of Cambodia, with the full powers duly entrusted to him, has signed this delegation of full power.

**PRIME MINISTER**

**h Akka Moha Sena Padei Techo HUN SEN**

# SECOND PROTOCOL TO AMEND THE AGREEMENT ON TRADE IN GOODS UNDER THE FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC COOPERATION AMONG THE GOVERNMENTS OF THE MEMBER COUNTRIES OF THE ASSOCIATION OF SOUTHEAST ASIAN NATIONS AND THE REPUBLIC OF KOREA

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member Countries of the Association of Southeast Asian Nations (hereinafter referred to collectively as "ASEAN" or "ASEAN Member Countries" or individually as "ASEAN Member Country"), and the Republic of Korea (hereinafter referred to as "Korea") (hereinafter referred to individually as "the Party" and collectively as "the Parties"),

**RECALLING** the Agreement on Trade in Goods under the Framework Agreement on Comprehensive Economic Cooperation Among the Governments of the Member Countries of the Association of Southeast Asian Nations and the Republic of Korea (hereinafter referred to as the "Agreement"), signed in Kuala Lumpur, Malaysia on the twenty-fourth day of August 2006;

**RECOGNISING** that nothing in the Agreement precludes Parties from unilaterally accelerating and/or improving tariff commitments made under the Agreement;

**DESIRING** to clarify the provisions related to the acceleration of the implementation of concessions and the incorporation of new goods into such concessions as referred to in

paragraph 2 of Article 6 of the Agreement, the unilateral acceleration of tariff reduction or elimination as referred to in paragraph 2 of Annex 1 of the Agreement, and the unilateral acceleration of tariff reduction and/or elimination of tariff lines placed in the Sensitive Track and the unilateral transfer of tariff lines from the Sensitive Track into the Normal Track as referred to in paragraph 6 of Annex 2 of the Agreement;

**SEEKING** to establish the terms and conditions for the acceleration of tariff reduction and/or elimination for tariff lines placed in the Normal Track and Sensitive Track, and to provide for such arrangements to be administratively annexed to the Agreement;

**NOTING** that Article 17 of the Agreement provides for any amendments thereto to be mutually agreed upon in writing by the Parties;

**HAVE AGREED** as follows:

## ARTICLE 1
## AMENDMENT TO INSERT A NEW ARTICLE 6 *bis* INTO THE AGREEMENT

The Agreement shall be amended by inserting a new Article 6 ***bis*** immediately after the existing Article 6 of the Agreement as follows:

"Article 6 ***bis***
Acceleration of Tariff Commitments

1. For the purpose of this Article, acceleration and/or improvement of tariff commitments may include incorporation of new goods into the tariff concessions made under this Agreement.

2. (a) A Party may unilaterally accelerate the reduction and/or elimination of tariffs on originating goods of the other Parties at any time if it so wishes as referred to in

paragraph 2 of Annex 1 or paragraph 6 of Annex 2 of the Agreement. Tariff concessions arising from such acceleration and/or elimination of tariff shall be extended to all Parties.

(b) Any Party may also unilaterally transfer any tariff line from the Sensitive Track into the Normal Track at any time if it so wishes as referred to in paragraph 6 of Annex 2 of the Agreement. Tariff concessions arising from improvement of tariff commitments shall be extended to all Parties.

3. Two or more Parties may also negotiate and enter into arrangement to accelerate and/or improve tariff commitments set out in their Schedules of tariff concessions made under this Agreement as referred to in paragraph 2 of Article 6 of the Agreement. Tariff concessions arising from such acceleration and/or improvement of tariff commitments shall be extended to all Parties.

4. Nothing in the Agreement shall preclude all Parties from negotiating and entering into arrangements to accelerate and/or improve tariff commitments made under this Agreement as referred to in paragraph 2 of Article 6 of this Agreement."

## ARTICLE 2
## AMENDMENT OF ARTICLE 17 OF THE AGREEMENT

Article 17 of the Agreement shall be amended and replaced by a new Article 17 as set out below:

### "Article 17
### Amendments

1. The provisions of this Agreement may be modified through amendments mutually agreed upon in writing by the Parties.

2. Each Party shall notify the other Parties in writing that its internal procedures necessary for the entry into force of the amendment have been completed. Such amendment shall enter into force on the first day of the second month following the date by which such notifications have been made by Korea and at least one ASEAN Member Country in relation to those Parties that have made such notification by that date.

3. Where any of the remaining ASEAN Member Country makes the notification as referred to in paragraph 2 after the date which the notifications have been made by Korea and at least one ASEAN Member Country as referred to in paragraph 2, the amendment referred to in paragraph 1 shall enter into force in relation to that ASEAN Member Country on the first day of the second month following the date on which it makes the notification.

4. Notwithstanding paragraphs 2 and 3, the number of ASEAN Member Countries as referred to in paragraph 2, which is the minimum required for the entry into force of the amendment, may be increased by agreement among all Parties.

5. Notwithstanding paragraphs 1 to 4[1]:

(a) In the case of amendments made in accordance with paragraph 2(a) of Article 6 *bis* of the Agreement, a Party shall notify all the other Parties through a diplomatic note immediately after completion of the internal procedures required for the amendments to

---

[1] In the case of Indonesia, in addition to the diplomatic note referred in subparagraphs (a), (b) and (c), a Letter of Understanding between Indonesia and that Party may be required and any amendment made to Appendices to Annexes 1, 2 and 3, and relevant attachments, shall enter into force upon the notification of the completion of its internal procedures.

enter into force. Such amendments shall enter into force on the date specified in the diplomatic note, or in any event, within 90 days of such notification. Any concessions granted by the Party according to the unilateral acceleration set out therein shall not be withdrawn.

(b) In the case of amendments made in accordance with paragraph 2(b) of Article 6 *bis* of the Agreement, a Party shall notify all the other Parties through a diplomatic note immediately after completion of the internal procedures required for the amendments to enter into force. Such amendments to the Appendices to Annex 2 of the Agreement shall enter into force on the date specified in the diplomatic note, or in any event, within 90 days of such notification. Once a Party unilaterally transfers any tariff line from the Sensitive Track into the Normal Track, that Party shall not transfer the tariff line back into the Sensitive Track. The Parties which have been informed of the unilateral transfer through the diplomatic note shall complete their internal procedures to terminate the application of the reciprocal tariff rate treatment for the corresponding tariff lines, if any, within 90 days of the date of receipt of the diplomatic note and notify all the other Parties upon the completion of such internal procedures through a diplomatic note. When a Party is not able to complete its internal procedures within the 90 day period provided herein, that Party shall notify all the other Parties, through a diplomatic note, of such failure to complete its internal procedures. In this case, additional 60 days may be given to that Party to do so, and that Party shall notify all the other Parties through a diplomatic note immediately after the completion of the internal procedures required for the amendments to enter into force.

(c) In the case of amendments made in accordance with paragraph 3 of Article 6 *bis* of the Agreement, each

Party making such amendment shall notify the other Parties, through a diplomatic note, immediately after completion of the internal procedures required for the amendments to enter into force. Such amendments shall enter into force on the date specified in that diplomatic note or on such other date the Parties involved may agree. Any concessions granted by the Parties according to the acceleration set out in the diplomatic note shall not be withdrawn.

6. Notwithstanding paragraphs 1 to 5, Appendices to Annex 3 and relevant Attachments of the Agreement may be modified through amendments endorsed by the Implementing Committee. Such amendments shall enter into force on such dates decided by the Implementing Committee. The Implementing Committee shall report the amendments to the AEM+Korea."

**ARTICLE 3**
**ENTRY INTO FORCE**

1. This Protocol shall form an integral part of the Agreement. It shall enter into force 90 days after the date by which Korea and at least one ASEAN Member Country have notified all the other Parties in writing of the completion of their internal procedures necessary for the entry into force of this Protocol.

2. Each Party, upon the completion of its internal procedures for the entry into force of this Protocol, shall notify all the other Parties in writing.

3. Where a Party is not able to complete its internal procedures for the entry into force of this Protocol by the entry into force date set out in paragraph 1, this Protocol shall enter into force in relation to that Party on the date of notification of completion of such internal procedures.

## ARTICLE 4
## DEPOSITARY

For the ASEAN Member Countries, this Protocol shall be deposited with the Secretary-General of ASEAN, who shall then promptly furnish a certified true copy thereof, to each ASEAN Member Country.

**IN WITNESS WHEREOF**, the undersigned being duly authorised by their respective Governments, have signed this Second Protocol to Amend the Agreement on Trade in Goods under the Framework Agreement on Comprehensive Economic Cooperation among the Governments of the Member Countries of the Association of Southeast Asian Nations and the Republic of Korea.

**DONE** at Bali, Indonesia, this 17th of November 2011, in duplicate copies in the English language.

| For the Government of Brunei Darussalam: | For the Government of the Republic of Korea: |
| --- | --- |
| **LIM JOCK SENG**<br>Second Minister of Foreign Affairs and Trade | **KIM SUNG-HWAN**<br>Minister of Foreign Affairs and Trade |

For the Royal Government of Cambodia:

**CHAM PRASIDH**
Senior Minister and Minister of Commerce

For the Government of the Republic of Indonesia:

**GITA WIRJAWAN**
Minister of Trade

For the Government of the Lao People's Democratic Republic:

**NAM VIYAKETH**
Minister of Industry and Commerce

For the Government of Malaysia:

**MUSTAPA MOHAMED**
Minister of International Trade and Industry

For the Government of the
Republic of the Union of Myanmar:

**U TIN NAING THEIN**
Union Minister, Ministry of National
Planning and Economic
Development

For the Government of the
Republic of the Philippines:

**GREGORY L. DOMINGO**
Secretary of Trade and Industry

For the Government of the
Republic of Singapore:

**LIM HNG KIANG**
Minister for Trade and Industry

For the Government of the
Kingdom of Thailand:

**KITTIRATT NA-RANONG**
Deputy Prime Minister and Minister
of Commerce

For the Government of the
Socialist Republic of Viet Nam:

**VU HUY HOANG**
Minister of Industry and Trade

# ពិធីសារកែប្រែកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលប្រទេសប្រ៊ុយណេដារ៉ូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ជារួមហៅថា "អាស៊ាន" ឬ "ប្រទេសសមា ជិកអាស៊ាន" ឬ ដោយឡែក "ប្រទេសសមាជិកអាស៊ាន" និងសាធារណរដ្ឋកូរ៉េ (ហៅថា "កូរ៉េ" ( ចំពោះសមាជិកមួយៗ ហៅថា "ភាគី" ជារួមហៅថា "បណ្តាភាគី")។

**ដោយរំលឹកឡើងវិញ** កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ (ហៅថា "កិច្ចព្រមព្រៀង") បានចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួរ ម៉ាឡេស៊ី នាថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៦

**ដោយរំលឹកឡើងវិញ** បន្ថែម ឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀង ដែលបានអនុញ្ញាតឲ្យភាគីនី' រក្សាសិទ្ធិ ដើម្បីរក្សាអត្រាពន្ធអនុវត្តសម្រាប់បន្ទាត់ពន្ធគយបានដាក់នៅក្នុងក្រុម ង នៃបញ្ជីវេ' ភាពខ្ពស់

**ការចង់បាន** បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនៃបន្ទាត់ពន្ធគយបានដាក់ទៅក្នុងបញ្ជីវេទយិតភាពខ្ពស់របស់សាធារណរដ្ឋប្រជាមានិតប្រជាធិតេយ្យឡាវ

**ដោយសម្គាល់ថា** មាត្រា ១៧ នៃកិច្ចព្រមព្រៀងបានចែងថាពល់ការកែប្រែណាមួយពីកិច្ចព្រមព្រៀងត្រូវមានការឯកភាពរវាងភាគីទាំងអស់ជាលាយលក្ខណ៍អក្សរដោយភាគីទាំងអស់។

***បានឯកភាពដូចតទៅ:***

## មាត្រា ១

**ទំសោធនកម្មលើឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀង**

សេចក្តីបន្ថែម ២ នៃឧបសម្ព័ន្ធ ២ របស់កិច្ចព្រមព្រៀង ពីនេះតទៅត្រូវកែប្រែ ដើម្បីបញ្ចូលបន្ទាត់ពន្ធគយបានដាក់នៅក្នុងក្រុម ង នៃបញ្ជីវេទយិតភាពខ្ពស់របស់សាធារណរដ្ឋប្រជាមានិតប្រជាធិតេយ្យឡាវទៅក្នុងកិច្ចព្រមព្រៀង។

## មាត្រា ២

## ការចូលជាធរមាន

១ ពិធីសារនេះត្រូវបញ្ចូលជាផ្នែកនៃកិច្ចព្រមព្រៀង។ វានឹងចូលជាធរមានកៅសិប (៩០) ថ្ងៃបន្ទាប់ពីថ្ងៃចុះហត្ថលេខា។

២ ភាគីនីមួយៗ នៅពេលបញ្ចប់នីតិវិធីផ្ទៃក្នុងសម្រាប់ចូលជាធរមាននៃពិធីសារនេះ ត្រូវជូនដំណឹងទៅភាគីឯទៀតៗជាលាយល័ក្ខអក្សរ។

៣ ភាគីណាមិនបានបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ចូលជាធរមាន ក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើពិធីសារនេះ ពិធីសារនេះនឹងចូលជាធរមានចំពោះភាគីនោះនៅថ្ងៃដែលភាគីបានជូនដំណឹងពីការបញ្ចប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួន។

## មាត្រា ៣

## ការតម្កល់ទុក

សម្រាប់ប្រទេសសមាជិកអាស៊ាន ពិធីសារនេះត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលអ្នកថតចម្លងច្បាប់ដើមរួចបញ្ជូនទៅឲ្យប្រទេសសមាជិកអាស៊ានដទៃទៀតជាបន្ទាន់។

**ជាសក្ខីភាព** ការចុះហត្ថលេខា ក្រោមអំណាចដ៏ត្រឹមត្រូវដោយភាគីនីមួយៗ បានចុះហត្ថលេខាលើពិធីសារនេះ ដើម្បីកែប្រែកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ក្នុងចំណោមប្រទេសសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ។

ធ្វើនៅបាងកក ថៃ នាថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ ជាភាសាអង់គ្លេសចំនួនពីរច្បាប់។

សម្រាប់រដ្ឋាភិបាលប្រ៊ុយណេ ឡារូសាឡាំ

LIM Jock Seng
រដ្ឋមន្ត្រីទី២ ក្រសួងការបរទេសនិងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាល សាធារណរដ្ឋកូរ៉េ

Kim Jong-Hoon
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

Cham Prasidh
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

Mari Elka Pangestu
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

Nam Viyaketh
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលម៉ាឡេស៊ី

Mustapa Mohamed

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

U Soe Tha

រដ្ឋមន្ត្រីក្រសួងផែនការជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

Gregory Domingo

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសិង្ហបុរី

Lim Hng Kiang

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលព្រះរាជាណាចក្រថៃ

Porntiva Nakasai

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

Vu Huy Hoang

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

# PROTOCOL TO AMEND THE AGREEMENT ON TRADE IN GOODS UNDER THE FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC COOPERATION AMONG THE GOVERNMENTS OF THE MEMBER COUNTRIES OF THE ASSOCIATION OF SOUTHEAST ASIAN NATIONS AND THE REPUBLIC OF KOREA

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member Countries of the Association of Southeast Asian Nations (hereinafter referred to collectively as "ASEAN" or "ASEAN Member Countries" or individually as "ASEAN Member Country"), and the Republic of Korea (hereinafter referred to as "Korea") (hereinafter referred to individually as "the Party" and collectively as "the Parties"),

**RECALLING** the Agreement on Trade in Goods under the Framework Agreement on Comprehensive Economic Cooperation Among the Governments of the Member Countries of the Association of Southeast Asian Nations and the Republic of Korea (hereinafter referred to as the "Agreement"), signed in Kuala Lumpur, Malaysia on the twenty fourth day of August 2006;

**RECALLING** further Annex 2 of the Agreement which allows each Party to reserve its right to maintain the applied tariff rates for the tariff lines placed in Group E of the Highly Sensitive List;

**DESIRING** to incorporate into the Agreement the tariff lines placed in Group E of the Highly Sensitive List of the Lao People's Democratic Republic;

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

**NOTING** that Article 17 of the Agreement provides for any amendments thereto to be mutually agreed upon in writing by the Parties,

**HAVE AGREED** as follows:

**Article 1**
**Amendment to Annex 2 of the Agreement**

Appendix 2 of Annex 2 to the Agreement is hereby amended to incorporate the tariff lines placed in Group E of the Highly Sensitive List of the Lao People's Democratic Republic.

**Article 2**
**Entry into Force**

1. This Protocol shall form an integral part of the Agreement. It shall enter into force ninety (90) days after the date of signing.

2. Each Party shall, upon the completion of its internal procedures for the entry into force of this Protocol, notify all the other Parties in writing.

3. Where a Party has not completed its internal procedures for the entry into force of this Protocol within 90 days after the date of signing of this Protocol, this Protocol shall enter into force in relation to that Party on the date of notification of completion of such internal procedures.

**Article 3**
**Depositary**

For the ASEAN Member Countries, this Protocol shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified true copy thereof, to each ASEAN Member Country.

CERTIFIED COPY
DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT

**IN WITNESS WHEREOF**, the undersigned, being duly authorised by their respective Governments, have signed this Protocol to Amend the Agreement on Trade in Goods under the Framework Agreement on the Comprehensive Economic Cooperation among the Governments of the Member Countries of the Association of the Southeast Asian Nations and the Republic of Korea.

**DONE** at Bangkok, Thailand, this 30th day of November 2010, in duplicate copies in the English language.

For the Government of Brunei Darussalam:

**LIM JOCK SENG**
Second Minister for Foreign Affairs and Trade

For the Government of the Republic of Korea:

**KIM JONG-HOON**
Minister for Trade

For the Royal Government of Cambodia:

**CHAM PRASIDH**
Senior Minister and Minister of Commerce





For the Government of the
Republic of Indonesia:

**MARI ELKA PANGESTU**
Minister of Trade

For the Government of the
Lao People's Democratic
Republic:

**NAM VIYAKETH**
Minister of Industry and
Commerce

For the Government of
Malaysia:

**MUSTAPA MOHAMED**
Minister of International Trade
and Industry

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

For the Government of the
Union of Myanmar:

**U SOE THA**
Minister for National Planning
and Economic Development

For the Government of the
Republic of the Philippines:

**GREGORY DOMINGO**
Secretary of Trade and Industry

For the Government of the
Republic of Singapore:

**LIM HNG KIANG**
Minister for Trade and Industry

For the Government of the
Kingdom of Thailand:

**PORNTIVA NAKASAI**
Minister of Commerce

For the Government of the
Socialist Republic of Viet Nam:

**VU HUY HOANG**
Minister of Industry and Trade



CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

# APPENDIX 2
# HIGHLY SENSITIVE LIST

**<u>GROUP E</u>**: Tariff lines exempted from tariff concession

Lao PDR:

| NO | HS CODE | DESCRIPTION |
|---|---|---|
| 1 | 2203.00 | Beer made from malt. |
| 2 | 2208.30 | - Whiskies: |
| 3 | 2402.20 | - Cigarettes containing tobacco: |
| 4 | 8702.10 | - With compression-ignition internal combustion piston engine (diesel or semi-diesel) |
| 5 | 8702.90 | - Other |
| 6 | 8703.10 | - Vehicles specially designed for travelling on snow; golf cars and similar vehicles |
| 7 | 8703.21 | - - Of a cylinder capacity not exceeding 1,000 cc |
| 8 | 8703.22 | - - Of a cylinder capacity exceeding 1,000 cc but not exceeding 1,500 cc |
| 9 | 8703.23 | - - Of a cylinder capacity exceeding 1,500 cc but not exceeding 3,000 cc |
| 10 | 8703.24 | - - Of a cylinder capacity exceeding 3,000 cc |
| 11 | 8703.31 | - - Of a cylinder capacity not exceeding 1,500 cc |
| 12 | 8703.32 | - - Of a cylinder capacity exceeding 1,500 cc but not exceeding 2,500 cc |
| 13 | 8703.33 | - - Of a cylinder capacity exceeding 2,500cc |
| 14 | 8703.90 | - Other |
| 15 | 8704.10 | - Dumpers designed for off-highway use |
| 16 | 8704.21 | - - Gross vehicle weight not exceeding 5t |
| 17 | 8704.22 | - - g.v.w exceeding 5t but not exceeding 20t |
| 18 | 8704.23 | - - g.v.w exceeding 20t |
| 19 | 8704.31 | - - g.w.w not exceeding 5t |
| 20 | 8704.32 | - - g.v.w. exceeding 5t |
| 21 | 8704.90 | - Other |
| 22 | 8706.00 | Chassis fitted with engines, for the motor vehicles of headings 87.01 to 87.05. |
| 23 | 8707.10 | - For the vehicles of 87.03 |
| 24 | 8707.90 | - Other |
| 25 | 8708.10 | - Bumpers and parts thereof |
| 26 | 8708.21 | - - Safety seat belts |
| 27 | 8708.29 | - - Other |
| 28 | 8711.10 | - With reciprocating internal combustion piston engine of a cylinder capacity not exceeding 50cc |
| 29 | 8711.20 | - With reciprocating internal combustion piston engine of a cylinder capacity exceeding 50cc but not exceeding 250cc |
| 30 | 8711.30 | - With reciprocating internal combustion piston engine of a cylinder capacity exceeding 250cc but not exceeding 500cc |
| 31 | 8711.40 | - With reciprocating internal combustion piston engine of a cylinder capacity exceeding 500cc but not exceeding 800cc |
| 32 | 8711.50 | - With reciprocating internal combustion piston engine of a cylinder capacity exceeding 800cc |
| 33 | 8711.90 | - Other |
| 34 | 8714.11 | - - Saddles |
| 35 | 8714.19 | - - Other |
| 36 | 8714.91 | - - Frames and forks, and parts thereof |
| 37 | 8714.92 | - - Wheel rims and spokes |
| 38 | 9504.10 | - Video games of a kind used with a television receiver |
| 39 | 9504.30 | - Other games, operated by coins, banknotes (paper currency), discs or other similar articles, other than bowling alley equipment |
| 40 | 9504.90 | - Other |

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

# ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៣៩៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :**

ត្រូវបានបញ្ចប់តំណែងរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ និងត្រូវបានកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា÷

**ក-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

| | |
|---|---|
| ១- ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី |
| ២-ឯកឧត្តម សាត សាមី | រដ្ឋលេខាធិការ |
| ៣-ឯកឧត្តម ភោគ សុវណ្ណរិទ្ធ | រដ្ឋលេខាធិការ |
| ៤-ឯកឧត្តម ឯក សុនចាន់ | រដ្ឋលេខាធិការ |
| ៥-ឯកឧត្តម ហេង សុខគង់ | រដ្ឋលេខាធិការ |
| ៦-លោកជំទាវ ឡាយ ណាវីន | រដ្ឋលេខាធិការ |
| ៧-ឯកឧត្តម គីម ទូច | រដ្ឋលេខាធិការ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ខ-ក្រសួងរ៉ែ និងថាមពល**

១- ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រី

២-ឯកឧត្តម អ៊ិត ប្រាំង រដ្ឋលេខាធិការ

៣-ឯកឧត្តម ហ៊ូ វិចិត្រ រដ្ឋលេខាធិការ

៤-ឯកឧត្តម ឌិត ទីណា រដ្ឋលេខាធិការ

៥-ឯកឧត្តម សុខ ខាវ៉ាន់ រដ្ឋលេខាធិការ

៦-ឯកឧត្តម ម៉េង សក្តិធារ៉ា រដ្ឋលេខាធិការ

៧-លោកជំទាវ ប៉ែន ឆដា រដ្ឋលេខាធិការ

**គ-ក្រសួងពាណិជ្ជកម្ម**

-ឯកឧត្តម អ៊ុក ប្រជា រដ្ឋលេខាធិការ

**ឃ-ក្រសួងទេសចរណ៍**

-ឯកឧត្តម ប៉ាក់ សុខុម រដ្ឋលេខាធិការ

**ង-ក្រសួងកិច្ចការនារី**

-លោកជំទាវ ស៊ីវណ្ណ បុទុម រដ្ឋលេខាធិការ

**ច-រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

-ឯកឧត្តម អ៊ុជ គឹមអន

**មាត្រា ២:**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរស. ១៣១២. ០៤១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣

លេខៈ១៣៧៤ស.ណ

**សំណៅចំលងចេញតាមច្បាប់ដើម**

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៣៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
| ៣-លោកជំទាវ | ចាន់ សុទ្ធាវី | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិកា |
| ៤-ឯកឧត្តម | ង៉ោ សុវណ្ណ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៥-ឯកឧត្តម | ព្រហ្ម សិទ្ធត្រា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦-ឯកឧត្តម | កើត រិទ្ធ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ឯកឧត្តម | គង់ ស្រ៊ីម | អនុប្រធានតុលាការកំពូល | សមាជិក |
| ៨-ឯកឧត្តម | ឈួន ចាន់ថា | អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល | សមាជិក |
| ៩-ឯកឧត្តម | យូ ប៊ុនឡេង | ប្រធានសាលាឧទ្ធរណ៍ | សមាជិក |
| ១០-ឯកឧត្តម | អ៊ុក សាវុធ | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | សមាជិក |
| ១១-ឯកឧត្តម | សុក ផេង | រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២-ឯកឧត្តម | ហ៊ាន សាហ៊ីប | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣-ឯកឧត្តម | ប៉ុល លឹម | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៤-ឯកឧត្តម | ម៉ៅ ថូរ៉ា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៥-ឯកឧត្តម | យូ ស៊ុនឡុង | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៦-ឯកឧត្តម | សម្បត្តិ ហ៊ុយណា | អគ្គនាយកនៃអគ្គនាយកដ្ឋានប្រតិបត្តិការ នៃអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ១៧-ឯកឧត្តម | អ៊ិត រ៉ាឌី | ប្រធានលេខាធិការដ្ឋាន | សមាជិក |

**មាត្រា២ .-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានតួនាទី និងភារកិច្ច ដូចមានចែងក្នុងអនុក្រឹត្យលេខ ៩៩១ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌជូនមន្ត្រីរាជការ ចំនួន ១២ រូប របស់ក្រសួង ចំនួន ០៣ ទៅក្នុងឋានន្តរស័ក្តិក្រមការនៃក្របខណ្ឌមន្ត្រីក្រមការ និងទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមនៃក្របខណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|
| **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៣ តទៅ | | | |
| ១ | លោក **ច័ន្ទ វណ្ណា** | ក្រមការ | ថ្នាក់លេខ ១១ |
| ២ | លោក **ឈន ឈុនលី** | ក្រមការ | ថ្នាក់លេខ ១១ |
| ៣ | លោកស្រី **ទ៉ោន សំណាង** | ក្រមការ | ថ្នាក់លេខ ១១ |
| ៤ | លោក **សម នារម្យ** | ក្រមការ | ថ្នាក់លេខ ១១ |
| ៥ | លោក **ដួង ចាន់ថ្លា** | ក្រមការ | ថ្នាក់លេខ ១១ |
| ៦ | លោក **ទិប សុខចេ** | ក្រមការ | ថ្នាក់លេខ ១១ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ តទៅ | | | |
| ៧ | លោក **ឈុន សារ៉ែន** | ក្រមការ | ថ្នាក់លេខ ១៤ |
| ៨ | លោក **នាង លីហ៊ាង** | ក្រមការ | ថ្នាក់លេខ ១៤ |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ តទៅ | | | |
| ៩ | លោកស្រី **ឌុំ ផានិត** | ក្រមការ | ថ្នាក់លេខ ១១ |
| ១០ | លោក **ហៀង សុយ៉ារ៉ូ** | ក្រមការ | ថ្នាក់លេខ ១១ |
| ១១ | លោកស្រី **ណុប រតនា** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |

| | | | |
|---|---|---|---|
| ១២ | លោក **ផន សុភាព** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតនេះទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ត្រូវបានដាក់មន្ត្រីរាជការ ចំនួន ៣ រូប របស់ក្រសួង ចំនួន ៣ ក្នុងឋានន្តរស័ក្តិវរមន្ត្រីនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្នុងឋានន្តរស័ក្តិវរមន្ត្រីការបរទេសនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ដែលបានដល់អាយុឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | មុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃ-ខែ-ឆ្នាំ ចូលនិវត្តន៍ |
|---|---|---|---|---|
| | **ក្រសួងទេសចរណ៍** | | | |
| ១ | លោក **អ៊ុំ ឃីម** | អគ្គនាយករង | វរមន្ត្រី ថ្នាក់លេខ ៥ | ០១-០៧-២០១៣ |
| | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | |
| ២ | លោក **ខន្ធ ដាច** | អនុប្រធាននាយកដ្ឋាន | វរមន្ត្រី ថ្នាក់លេខ ៧ | ០១-០២-២០១៣ |
| | **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (សុំចូលនិវត្តន៍មុនអាយុកំណត់)** | | | |
| ៣ | លោក **អេង ហ៊ិន** | អតីតអគ្គកុងស៊ុល | វរមន្ត្រីការបរទេស ថ្នាក់លេខ ៥ | ០១-១៦-២០១៣ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ០៣.សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **គាត ឈន់** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ | ប្រធាន |
| ២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **ជា ចាន់តូ** | ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **ហ៊ាន សាហ៊ីប** | អនុប្រធាននៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធាន |
| ៥- ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | សមាជិក |
| ៦- ឯកឧត្តមទេសរដ្ឋមន្ត្រី **ឆាយ ថន** | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |

| | | |
|---|---|---|
| ៧- ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨- ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០- ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១១- ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១២- ឯកឧត្តម **ត្រាក់ សុខុន** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៣-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៤- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៥- ឯកឧត្តមរដ្ឋមន្ត្រី **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៦- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៧-ឯកឧត្តម **ទន្សី ចិស្សូត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ២.-**

ឯកឧត្តម **ផាន់ ផល្លា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ៤
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៤ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ | ប្រធាន |
| ២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

| | |
|---|---|
| ៦- តំណាងក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន | សមាជិក |
| ៧- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៩- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០- តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១១- គណៈកម្មការប្រឹក្សាការងារ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវកត្តាគន្លឹះសំខាន់ៗជាមូលដ្ឋាន ក្នុងការរៀបចំប្រាក់ឈ្នួលអប្បរមាសម្រាប់កម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ។
- សហការជាមួយដៃគូអភិវឌ្ឍន៍ទាំងរដ្ឋាភិបាល និងវិស័យឯកជននានាដែលពាក់ព័ន្ធ។
- ផ្តល់ជម្រើសស្តីពីការរៀបចំកម្រិតប្រាក់បៀវត្សអប្បបរមារយៈពេលខ្លី មធ្យម និងរយៈពេលវែង ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេច ។

**ប្រការ ៣.-**

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់មន្ត្រីជំនាញក្រោមឱវាទជាជំនួយការ ។

**ប្រការ ៤.-**

ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រធានសភាពាណិជ្ជកម្មកម្ពុជា គណៈកម្មការប្រឹក្សាការងារ និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..០៣៣០....សហវ.ប្រក.

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះ**

**អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣/ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណង ដូចខាងក្រោម ÷

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- រៀបចំតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងការគ្រប់គ្រង និងត្រួតពិនិត្យវិស័យធានារ៉ាប់រងនិងសោធន ទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ អាជីវកម្មភ្នាល់គ្រប់ប្រភេទ អាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ព្រមទាំងចូលរួមប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើបេសកកម្មអនុវត្តការគ្រប់គ្រង និងត្រួតពិនិត្យ វិស័យធានារ៉ាប់រងនិងសោធន ទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ អាជីវកម្មភ្នាល់គ្រប់ប្រភេទ អាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន និងចូលរួមប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**ប្រការ៥.-**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷

- រៀបចំសម្របសម្រួល និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារធានារ៉ាប់រង និងសោធន
- ចូលរួមគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញប្បទានរបស់រដ្ឋដែលគាំទ្រការអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងសម្របសម្រួលលើការអនុវត្តគោលនយោបាយឥណទានអភិវឌ្ឍជនបទ
- គ្រប់គ្រង ត្រួតពិនិត្យ ចុះបញ្ជី និងរក្សាបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ
- គ្រប់គ្រង និងត្រួតពិនិត្យ សេវាកម្មវាយតម្លៃ សេវាកម្មទិញ-លក់ ជួលអចលនវត្ថុ និងបុគ្គលអភិវឌ្ឍលំនៅឋាន
- គ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ ទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- គ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលចំណូលពីអាជីវកម្មកាស៊ីណូ និងអាជីវកម្មភ្នាល់គ្រប់ប្រភេទដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល
- សហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីថ្នាក់ដឹកនាំក្រសួង។

**ប្រការ៦.-**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ និងលេខាធិការដ្ឋានចំនួន ១ ដូចខាងក្រោម ÷

- នាយកដ្ឋានធានារ៉ាប់រង និងសោធន

- នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- លេខាធិការដ្ឋាន

នាយកដ្ឋាននីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់

អង្គការលេខរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៧.-**

- នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ
- លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យ
- ការិយាល័យចំណុះនាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូបដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

## ជំពូកទី៣
## នាយកដ្ឋានធានារ៉ាប់រងនិងសោធន

**ប្រការ៨.-**

នាយកដ្ឋានធានារ៉ាប់រង និងសោធន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុលើការងារគ្រប់គ្រងធានារ៉ាប់រង និងសោធន ដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យធានារ៉ាប់រងនៅកម្ពុជា និងសមាហរណកម្មវិស័យនេះក្នុងក្របខណ្ឌអាស៊ាន និងសកលលោក
- គ្រប់គ្រង ត្រួតពិនិត្យ ផ្តល់អាជ្ញាបណ្ណ បន្តសុពលភាពអាជ្ញាបណ្ណធានារ៉ាប់រង និង បោះពុម្ពរបាយការណ៍ប្រចាំឆ្នាំស្តីពីការធានារ៉ាប់រង
- កំណត់ទណ្ឌកម្មវិន័យ និងវិធានការរដ្ឋបាលចំពោះអាជីវកម្មធានារ៉ាប់រង និងសោធន និងដំណើរការយន្តការផ្សះផ្សាវិវាទក្នុងវិស័យធានារ៉ាប់រង
- បង្កើត និងគ្រប់គ្រងមូលនិធិធានារ៉ាប់រងដើម្បីជំរុញការអភិវឌ្ឍវិស័យធានារ៉ាប់រង
- រៀបចំបណ្តុះបណ្តាលវគ្គជំនាញធានារ៉ាប់រង និងសោធនសម្រាប់បញ្ញត្តិករធានារ៉ាប់រង ប្រតិបត្តិករធានារ៉ាប់រង និងអត្ថគាហកៈ
- បន្តពង្រឹង និងពង្រីកប្រព័ន្ធសុវត្ថិភាពសង្គម តាមរយៈការអភិវឌ្ឍវិស័យធានារ៉ាប់រង សោធន បេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល មូលនិធិជនពិការ ព្រមទាំងមូលនិធិ ឬបេឡាដទៃផ្សេងទៀតដែលជាគ្រឹះស្ថានសាធារណៈរបស់រដ្ឋ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ៩.-**

នាយកដ្ឋានធានារ៉ាប់រង និងសោធន មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម៖

- ការិយាល័យត្រួតពិនិត្យ

- ការិយាល័យនីតិកម្ម និងដោះស្រាយវិវាទ
- ការិយាល័យអភិវឌ្ឍន៍ទីផ្សារ
- ការិយាល័យសោធន

**ប្រការ១០.-**

ការិយាល័យត្រួតពិនិត្យ មានភារកិច្ចដូចតទៅ ÷

- រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យវិស័យធានារ៉ាប់រង និងសោធនដោយអនុលោមតាមស្តង់ដារសមាគមអន្តរជាតិនៃអ្នកត្រួតពិនិត្យធានារ៉ាប់រង
- តាមដានជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុ និងអាជីវកម្មរបស់គ្រឹះស្ថានធានារ៉ាប់រង និងសោធន
- រៀបចំស្វ័យវាយតម្លៃជាប្រចាំលើប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យធានារ៉ាប់រង និងសោធនអនុលោមតាមគោលការណ៍ធានារ៉ាប់រង
- សិក្សាវិភាគនៅនឹងកន្លែង និងចុះត្រួតពិនិត្យជាក់ស្តែងលើស្ថានភាពហិរញ្ញវត្ថុប្រចាំឆ្នាំរបស់គ្រឹះស្ថានធានារ៉ាប់រង
- ចូលរួមតាមដានសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យធានា-រ៉ាប់រង និងសោធន
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុ និងអាជីវកម្មរបស់គ្រឹះស្ថានធានារ៉ាប់រងជូនថ្នាក់ដឹកនាំឱ្យបានទាន់ពេលវេលា
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១១.-**

ការិយាល័យនីតិកម្ម និងដោះស្រាយវិវាទ មានភារកិច្ចដូចតទៅ÷

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិប្រុងប្រយ័ត្នចាំបាច់នានា ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យវិស័យធានារ៉ាប់រងនិងសោធន និងសមាហរណកម្មវិស័យធានារ៉ាប់រង និងសោធនក្នុងក្របខ័ណ្ឌអាស៊ាន
- ការពារ និងដោះស្រាយវិវាទជូនអ្នកត្រូវបានធានារ៉ាប់រង
- បណ្តុះបណ្តាលក្រមសីលធម៌វិជ្ជាជីវៈ និងពង្រឹងអភិបាលកិច្ចសម្រាប់គ្រឹះស្ថានធានារ៉ាប់រង
- រៀបចំតែងតាំងស្នងការគណនីឯករាជ្យ និងដំណើរការជម្រះបញ្ជីគ្រឹះស្ថានធានារ៉ាប់រង
- រៀបចំការផ្តល់អាជ្ញាបណ្ណ និងបន្តអាជ្ញាបណ្ណ ជូនក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង និងអ្នកគណនាវាយតម្លៃហានិភ័យធានារ៉ាប់រង
- រៀបចំលក្ខខណ្ឌវិនិច្ឆ័យលើការតែងតាំងគណៈនាយក និងនាយកប្រតិបត្តិរបស់គ្រឹះស្ថានធានារ៉ាប់រង
- សហការជាមួយការិយាល័យត្រួតពិនិត្យ រៀបចំការដាក់ពិន័យចំពោះគ្រឹះស្ថានធានារ៉ាប់រងណាដែលប្រព្រឹត្តល្មើស និងរៀបចំសំណុំរឿងពាក់ព័ន្ធ និងពាក្យបណ្តឹងទៅតុលាការ
- សហការជាមួយការិយាល័យអភិវឌ្ឍន៍ទីផ្សារ ដើម្បីធ្វើការចុះផ្សព្វផ្សាយនៅក្នុងរបាយការណ៍ធានារ៉ាប់រងប្រចាំឆ្នាំនូវការផ្តល់អាជ្ញាបណ្ណ ឬការចេញលិខិតបទដ្ឋានស្តីពីការធានារ៉ាប់រង
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១២.-**

ការិយាល័យអភិវឌ្ឍន៍ទីផ្សារ មានភារកិច្ចដូចតទៅ÷

- រៀបចំ និងបោះផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់ទីផ្សារធានារ៉ាប់រង
- រៀបចំនីតិវិធីអនុម័តលើសំណើសុំផលិតផលធានារ៉ាប់រង
- រៀបចំបង្កើត និងគ្រប់គ្រងទិន្នន័យរបស់គ្រឹះស្ថានធានារ៉ាប់រង និងសោធន
- រៀបចំ ថែទាំ និងធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា បណ្តាញព័ត៌មានវិទ្យា ផ្តល់ព័ត៌មាន និងទិន្នន័យធានារ៉ាប់រងដល់គ្រប់ការិយាល័យទាំងអស់នៅក្នុងនាយកដ្ឋានធានារ៉ាប់រងនិងសោធន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតតាមសំណើ
- សហប្រតិបត្តិការជាមួយសមាគមធានារ៉ាប់រងជាតិ និងអាស៊ានលើកិច្ចការធានារ៉ាប់រង និងសោធន
- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងរៀបចំការផ្សព្វផ្សាយការធានារ៉ាប់រងដល់សាធារណជន
- ធ្វើការសិក្សាស្រាវជ្រាវការវិវត្តរបស់វិស័យធានារ៉ាប់រងនៅក្នុងតំបន់ និងពិភពលោក
- សរុប និងរៀបចំរបាយការណ៍ធានារ៉ាប់រងអាស៊ាន និងសកម្មភាពរួមប្រចាំខែនីមួយៗ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១៣.-**

ការិយាល័យសោធន មានភារកិច្ចដូចតទៅ÷

- រៀបចំ និងអនុវត្តគោលនយោបាយ និងផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព
- រៀបចំក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងគម្រោងសោធនស្ម័គ្រចិត្តពីផ្នែកឯកជន
- រៀបចំផ្តល់នីតិភាព គ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិកររបស់សោធននៅកម្ពុជា
- វិភាគ និងតាមដានស្ថានភាពហិរញ្ញវត្ថុរបស់វិស័យសោធន រួមមាន÷ បេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងមូលនិធិជនពិការ
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃវិស័យសោធនដល់សាធារណជន
- កសាងសមត្ថភាពមន្ត្រីជំនាញសម្រាប់គ្រប់គ្រង និងត្រួតពិនិត្យវិស័យសោធន
- ធ្វើរបាយការណ៍ប្រចាំខែជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី៤
## នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ

**ប្រការ១៤.-**

នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លើការងារគ្រប់គ្រងទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ ដូចខាងក្រោម÷

- រៀបចំក្របខណ្ឌគតិយុត្ត ដើម្បីបោះផ្សាយ និងគ្រប់គ្រងមូលបត្ររដ្ឋ និងសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ
- អភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ សហគ្រាសធុនតូច និងមធ្យម
- គ្រប់គ្រង និងត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

- គ្រប់គ្រង និងត្រួតពិនិត្យ ការប្រើប្រាស់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្មដោយសហការជាមួយធនាគារអភិវឌ្ឍន៍ជនបទ
- សិក្សា និងរៀបចំយន្តការហិរញ្ញប្បទានមូលបត្រ ទីផ្សារខុម្ម័ឌីធីអនាគត មូលនិធិទ្រព្យអធិបតេយ្យ និងមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ
- តាមដានអំពីដំណើរវិវត្ត និងនិន្នាការនៃទីផ្សារហិរញ្ញវត្ថុនៅក្នុងតំបន់ និងពិភពលោក ដើម្បីដាក់ចេញនូវគោលនយោបាយថ្មីៗគាំទ្រដល់ការអភិវឌ្ឍទីផ្សារក្នុងស្រុក
- រៀបចំរបាយការណ៍វឌ្ឍនភាពជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ជាលេខាធិការដ្ឋាននៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ (គជទាន) រៀបចំក្របខណ្ឌគោលនយោបាយ គ្រប់គ្រង តាមដាន និងសម្របសម្រួលគំរោងហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍសម្រាប់អភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុ និង សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១៥.-**

នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ មានការិយាល័យក្រោមឱវាទចំនួន៤ ដូចខាងក្រោម ÷

- ការិយាល័យមីក្រូហិរញ្ញវត្ថុ និងបរធនបាលកិច្ចហិរញ្ញវត្ថុ
- ការិយាល័យហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច និងមធ្យម
- ការិយាល័យអភិវឌ្ឍន៍ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ
- ការិយាល័យសមាហរណកម្មវិស័យហិរញ្ញវត្ថុ

**ប្រការ១៦.-**

ការិយាល័យមីក្រូហិរញ្ញវត្ថុ និងបរធនបាលកិច្ចហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ÷

- តាមដាន និងអនុវត្តគោលនយោបាយស្តីពីវិស័យមីក្រូហិរញ្ញវត្ថុក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រង តាមដាន និងត្រួតពិនិត្យហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍនៅក្នុងគ្រឹះស្ថានធនាគារមីក្រូហិរញ្ញវត្ថុ និងស្ថាប័នផ្សេងទៀត
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនៃការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ពិនិត្យ និងផ្តល់វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ
- គ្រប់គ្រង និងត្រួតពិនិត្យស្ថានភាពបរធនបាលកិច្ចហិរញ្ញវត្ថុ
- សម្របសម្រួល និងចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីកៀរហិរញ្ញប្បទានពីប្រភពក្នុងស្រុក និងដៃគូអភិវឌ្ឍន៍នានាសម្រាប់គាំទ្រវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា
- ចូលរួម និងសហការរៀបចំប្រជុំ សិក្ខាសាលា សន្និសីទអំពីវឌ្ឍនភាពនៃវិស័យមីក្រូហិរញ្ញវត្ថុ
- សម្របសម្រួល និងដោះស្រាយវិវាទដែលកើតមានក្នុងការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ
- ចូលរួមតាមដានសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងប្រតិបត្តិការពាក់ព័ន្ធនឹងបរធនបាលកិច្ចហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ និងរបាយការណ៍វឌ្ឍភាពវិស័យមីក្រូហិរញ្ញវត្ថុ បរធនបាលកិច្ចហិរញ្ញវត្ថុជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជ្រាប និងផ្តល់ការណែនាំ

- ជាសេនាធិការឱ្យនាយកដ្ឋាន ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការឥណទានសម្រាប់អភិវឌ្ឍន៍ជនបទ (គជទាន)
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១៧.-**

ការិយាល័យហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច និងមធ្យម មានភារកិច្ចដូចតទៅ÷

- ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពី ការផ្តល់ហិរញ្ញប្បទានគាំទ្រសហគ្រាសធុនតូច និងមធ្យម
- ចូលរួមរៀបចំក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិគតិយុត្តនានា សម្រាប់អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- គ្រប់គ្រង និងតាមដានគម្រោងហិរញ្ញប្បទានពីប្រភពផ្សេងៗគាំទ្រដល់វិស័យសហគ្រាសធុនតូចនិងមធ្យម វិស័យកសិកម្ម និងកសិឧស្សាហកម្ម
- រៀបចំតាមដាន និងត្រួតពិនិត្យការស៊ីខ្ចីប្រាក់ ការសងប្រាក់ ការបង់ការប្រាក់របស់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម គាំទ្រដល់វិស័យស្រូវ-អង្ករ និងកសិឧស្សាហកម្ម
- រៀបចំរបាយការណ៍វឌ្ឍនភាពជូនថ្នាក់ដឹកនាំពិនិត្យ និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១៨.-**

ការិយាល័យអភិវឌ្ឍន៍ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ÷

- រៀបចំ និងអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ
- សម្របសម្រួលការបោះផ្សាយសញ្ញាប័ណ្ណបំពេញដើមទុនជូនសហគ្រាសរដ្ឋ
- សិក្សា តាមដាន និងធ្វើសហប្រតិបត្តិការជាមួយផ្នែកជំនាញនៃស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិលើការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុកម្ពុជា
- ស្រាវជ្រាវ និងអភិវឌ្ឍយន្តការវាយតម្លៃកម្រិតឥណទាន ទីផ្សារខុម្ម៉ូឌីធី ហិរញ្ញប្បទានមូលបត្រ មូលនិធិរដ្ឋអធិបតេយ្យ មជ្ឈមណ្ឌលអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- សម្របសម្រួលការងារ ពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងជាលេខាធិការដ្ឋានគណៈកម្មការបច្ចេកទេសអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១៩.-**

ការិយាល័យសមាហរណកម្មវិស័យហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ÷

- សម្របសម្រួលការធ្វើ IPO របស់សហគ្រាសរដ្ឋក្នុងទីផ្សារមូលបត្រកម្ពុជា
- សម្របសម្រួលការងាររបស់លេខាធិការដ្ឋាននៃយន្តការគ្រប់គ្រងវិបត្តិក្នុងវិស័យហិរញ្ញវត្ថុ
- សម្របសម្រួលការងារផ្សេងៗពាក់ព័ន្ធនឹងសមាហរណកម្មវិស័យហិរញ្ញវត្ថុ
- ស្រាវជ្រាវ និងអភិវឌ្ឍយន្តការធានារ៉ាប់រងលើប្រាក់បញ្ញើ (Deposit Insurance)

- តាមដាន និងចូលរួមកិច្ចប្រជុំពាក់ព័ន្ធក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ានបូក៣
- សិក្សា តាមដាន និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នក្នុងស្រុក និងអន្តរជាតិក្នុងការធ្វើសមាហរណកម្មទីផ្សារហិរញ្ញវត្ថុកម្ពុជានៅក្នុងតំបន់ និងពិភពលោក
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី៥
## នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

**ប្រការ២០.-**

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លើការងារគ្រប់គ្រងអាជីវកម្មភ្នាល់គ្រប់ប្រភេទ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដូចខាងក្រោម ÷

- រៀបចំក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត និងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មកាស៊ីណូ ឆ្នោតឡូតូ និងល្បែងផ្សងសំណាងគ្រប់ប្រភេទ
- ផ្តល់អាជ្ញាបណ្ណ បន្តសុពលភាពអាជ្ញាបណ្ណ ដកហូតអាជ្ញាបណ្ណ និងផ្តល់ការសម្រេចលើឧបករណ៍ល្បែងផ្សងសំណាងគ្រប់ប្រភេទ និងកំណត់ទណ្ឌកម្មវិន័យ និងវិធានការរដ្ឋបាលចំពោះអាជីវកម្មកាស៊ីណូ និងល្បែងផ្សងសំណាងគ្រប់ប្រភេទ
- ប្រមូលកាតព្វកិច្ចចំណូលពីអាជីវកម្មកាស៊ីណូ ឆ្នោតឡូតូ និងល្បែងផ្សងសំណាងគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មល្បែងផ្សងសំណាងខុសច្បាប់ ការអនុញ្ញាតឱ្យពលរដ្ឋខ្មែរចូលលេងល្បែងក្នុងបរិវេណកាស៊ីណូ និងការបំលាស់ទីឧបករណ៍ល្បែងផ្សងសំណាងខុសច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំផែនការចំណូលប្រចាំឆ្នាំ ពីអាជីវកម្មកាស៊ីណូ ឆ្នោតឡូតូ និងល្បែងផ្សងសំណាងគ្រប់ប្រភេទជូនថ្នាក់ដឹកនាំក្រសួងពិនិត្យសម្រេច និងផ្តល់ការណែនាំ
- កំណត់វិធាន នីតិវិធី និងចាត់វិធានការទប់ស្កាត់ និងបង្ក្រាបការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងក្រុមការងារអាស៊ីប៉ាស៊ីហ្វិក ដើម្បីបំពេញកាតព្វកិច្ចសមាជិកភាពរបស់កម្ពុជា
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ២១.-**

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម ÷

- ការិយាល័យបង្ក្រាបអាជីវកម្មខុសច្បាប់
- ការិយាល័យចុះបញ្ជីអាជីវកម្ម និងគ្រប់គ្រងបច្ចេកទេស

- ការិយាល័យគ្រប់គ្រងចំណូលទី ១
- ការិយាល័យគ្រប់គ្រងចំណូលទី ២

**ប្រការ២២.-**

ការិយាល័យបង្ក្រាបអាជីវកម្មខុសច្បាប់ មានភារកិច្ចដូចតទៅ÷

- រៀបចំក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត កំណត់ទិស និងនីតិវិធីនៃការគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្ម អាជីវកម្មឆ្នោត-ឡូតូ កាស៊ីណូ ល្បែងភ្នាល់តាមអ៊ិនធើណែត និងល្បែងភ្នាល់គ្រប់ប្រភេទ
- ចុះត្រួតពិនិត្យ និងចាត់វិធានការបង្ក្រាប ចំពោះក្រុមហ៊ុនឆ្នោត-ឡូតូ កាស៊ីណូ ភ្នាល់បាល់ ភ្នាល់បក្សី ( ជល់មាន់ ) ល្បែងភ្នាល់តាមអ៊ិនធើណែត និង ល្បែងភ្នាល់គ្រប់ប្រភេទ ដែលទទួលបានគោលការណ៍អនុញ្ញាត (សជណ) តែមិនមានអាជ្ញាបណ្ណរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំនីតិវិធី និងអនុវត្តការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅក្នុងទីតាំងអាជីវកម្មឆ្នោត-ឡូតូ កាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទដែលស្ថិតក្នុងបរិវេណកាស៊ីណូ
- ចាត់វិធានការតាមផ្លូវច្បាប់ ចំពោះក្រុមហ៊ុនអាជីវកម្ម ឆ្នោត-ឡូតូ កាស៊ីណូ ល្បែងភ្នាល់គ្រប់ប្រភេទដែលពុំបានបំពេញកាតព្វកិច្ចបង់ចំណូលជូនរដ្ឋ
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗ ទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ២៣.-**

ការិយាល័យចុះបញ្ជីអាជីវកម្ម និងគ្រប់គ្រងបច្ចេកទេស មានភារកិច្ចដូចតទៅ÷

- រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្តល់អាជ្ញាបណ្ណ បន្តសុពលភាពអាជ្ញាបណ្ណ និងដកហូតអាជ្ញាបណ្ណចំពោះក្រុមហ៊ុនអាជីវកម្មឆ្នោត-ឡូតូ កាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទ ដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល
- ត្រួតពិនិត្យរាល់ឯកសារកិច្ចសន្យាជួល ផ្ទេរ ឬ លក់កាស៊ីណូ ឬអាជ្ញាបណ្ណនៃក្រុមហ៊ុនអាជីវកម្មឆ្នោត-ឡូតូ កាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទ
- គ្រប់គ្រង និងត្រួតពិនិត្យ ការលក់/ផ្ទេរភាគហ៊ុន ឬ ប្តូរទីតាំងធ្វើអាជីវកម្ម និងការផលិតឧបករណ៍ល្បែង ឬ សម្ភារៈល្បែង ឬ ការចល័តឧបករណ៍ល្បែង ឬ សម្ភារៈល្បែងពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត
- គ្រប់គ្រង និងត្រួតពិនិត្យឧបករណ៍-សំភារៈល្បែង វិធាននៃល្បែង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (CCTV) នៅក្នុងទីតាំងធ្វើអាជីវកម្មឆ្នោត-ឡូតូ និងកាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទ
- រៀបចំបែបបទក្នុងការនាំចូល សម្ភារៈល្បែង ឬឧបករណ៍ល្បែងគ្រប់ប្រភេទ
- ធ្វើរបាយការណ៍ប្រចាំខែជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ២៤.-**

ការិយាល័យគ្រប់គ្រងចំណូលទី ១ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង និងប្រមូលចំណូលពីអាជីវកម្ម ឆ្នោត-ឡូតូ និង ល្បែងភ្នាល់គ្រប់ប្រភេទ

- គ្រប់គ្រង និងប្រមូលចំណូលពីអាជីវកម្មកាស៊ីណូនៅតាមតំបន់ព្រំដែនកម្ពុជា-វៀតណាម និងកាស៊ីណូនៅរាជធានីភ្នំពេញ
- ចុះត្រួតពិនិត្យសកម្មភាពអាជីវកម្ម ឆ្នោត-ឡូតូ កាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទ
- តាមដាន និង ជំរុញការបង់ចំណូលជូនរដ្ឋឱ្យបានទៀងទាត់ និងទាន់ពេលវេលា
- ចាត់វិធានការរដ្ឋបាល និងផាកពិន័យ ចំពោះក្រុមហ៊ុនឆ្នោត-ឡូតូ និងកាស៊ីណូទាំងឡាយណាដែលយឺតយ៉ាវក្នុងការបំពេញកាតព្វកិច្ចបង់ចំណូលជូនរដ្ឋ និងមិនគោរពតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ២៥.-**

ការិយាល័យគ្រប់គ្រងចំណូលទី ២ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង ប្រមូលចំណូល និងចុះត្រួតពិនិត្យសកម្មភាពអាជីវកម្មកាស៊ីណូនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ ខេត្តព្រះសីហនុ និងតំបន់ផ្សេងទៀត
- តាមដាន និង ជំរុញការបង់ចំណូលជូនរដ្ឋឱ្យបានទៀងទាត់ និងទាន់ពេលវេលា
- ចាត់វិធានការរដ្ឋបាល និងផាកពិន័យចំពោះក្រុមហ៊ុនកាស៊ីណូទាំងឡាយណា ដែលយឺតយ៉ាវក្នុងការបំពេញកាតព្វកិច្ចបង់ចំណូលជូនរដ្ឋ និងមិនគោរពតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី ៦
## នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន

**ប្រការ២៦.-**

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លើការងារគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដូចខាងក្រោម÷

- រៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព គោលនយោបាយចាំបាច់នានា សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មអចលនវត្ថុ អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីគាំទ្រការអភិវឌ្ឍន៍វិស័យអចលនវត្ថុ និងវិស័យទទួលបញ្ចាំនៅកម្ពុជា
- គ្រប់គ្រង ត្រួតពិនិត្យ ផ្តល់អាជ្ញាបណ្ណ បន្តសុពលភាពអាជ្ញាបណ្ណ ដកហូតអាជ្ញាបណ្ណ និងកំណត់ទណ្ឌកម្មវិន័យ និងវិធានការរដ្ឋបាលចំពោះអាជីវកម្មទិញ លក់ ជួល និងអភិវឌ្ឍន៍អចលនវត្ថុ និងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- ប្រមូលចំណូលអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ និងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មទិញ លក់ ជួល និងអភិវឌ្ឍន៍អចលនវត្ថុ និងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខុសច្បាប់ ដែលគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្សះផ្សា និង ដោះស្រាយរាល់វិវាទ ដែលទាក់ទងនឹងការទិញ លក់ ជួលអចលនវត្ថុ ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- រៀបចំបង្កើតអោយមានវេទិកាដេញថ្លៃលើទ្រព្យបញ្ចាំ និងទ្រព្យប្រាតិភោគដោយអនុប្បទាន
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ២៧.-**

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម ÷

- ការិយាល័យសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ
- ការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន
- ការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ
- ការិយាល័យស្រាវជ្រាវ និងបង្ក្រាបបទល្មើសអាជីវកម្ម

**ប្រការ២៨.-**

ការិយាល័យសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ មានភារកិច្ចដូចតទៅ÷

- រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ
- គ្រប់គ្រង ត្រួតពិនិត្យ និងផ្តល់អាជ្ញាបណ្ណ និងវិញ្ញាបនប័ត្រវិជ្ជាជីវៈដល់ក្រុមហ៊ុនផ្តល់សេវាកម្មវាយតំលៃ និងភ្នាក់ងារអចលនវត្ថុ
- ចុះត្រួតពិនិត្យដល់ទីកន្លែងជាប្រចាំ ឬក្នុងករណីមានភាពមិនប្រក្រតី ឬក្នុងករណីមានបណ្តឹង
- ប្រមូលចំណូលថ្លៃអាជ្ញាបណ្ណរបស់ក្រុមហ៊ុនវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ
- ដោះស្រាយរាល់វិវាទដែលជាបណ្តឹងតវ៉ារបស់អតិថិជនជាមួយនឹងក្រុមហ៊ុន ដែលទទួលបានអាជ្ញាបណ្ណ
- ផ្សព្វផ្សាយព័ត៌មាននានាពាក់ព័ន្ធទៅនឹងតម្លៃទីផ្សារអចលនវត្ថុ និងការអភិវឌ្ឍន៍អចលនវត្ថុ
- រៀបចំកម្មវិធីបណ្តុះបណ្តាល ពង្រឹងសមត្ថភាពអ្នកកាន់អាជ្ញាបណ្ណសេវាកម្មវាយតំលៃ ឬជាភ្នាក់ងារអចលនវត្ថុ និងអ្នកកាន់អាជ្ញាបណ្ណ
- ធ្វើរបាយការណ៍លើការគ្រប់គ្រង និងត្រួតពិនិត្យភ្នាក់ងារអចលនវត្ថុ និងវាយតំលៃអចលនវត្ថុប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗ ទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ២៩.-**

ការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន មានភារកិច្ចដូចតទៅ÷

- រៀបចំលិខិតបទដ្ឋានគតិយុត្តនានាដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន
- ពិនិត្យផ្តល់អាជ្ញាបណ្ណជូនដល់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាន
- គ្រប់គ្រង និងពិនិត្យលើឯកសារស្នើសុំផ្សាយពាណិជ្ជកម្មលក់លំនៅឋានរបស់ក្រុមហ៊ុន
- គ្រប់គ្រង និងតាមដានការប្រើប្រាស់គណនីអភិវឌ្ឍន៍លំនៅឋានរបស់ក្រុមហ៊ុន
- គ្រប់គ្រង និងប្រមូលថ្លៃអាជ្ញាបណ្ណរបស់អ្នកអភិវឌ្ឍន៍លំនៅឋាន
- ចូលរួមដោះស្រាយរាល់វិវាទនានា ដែលទាក់ទងនឹងការប្តឹងផ្តល់របស់អតិថិជនជាមួយនឹងក្រុមហ៊ុនដែលទទួលអាជ្ញាបណ្ណអភិវឌ្ឍន៍លំនៅឋាន
- ចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងអភិវឌ្ឍន៍លំនៅឋានជាប្រចាំ ឬទៅតាមការចាំបាច់ ឬក្នុងករណីមានបណ្តឹង
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗ ទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ៣០.-**

កាវិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ មានភារកិច្ចដូចតទៅ÷

- រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និងអាជីវកម្មទិញ-លក់ទំនិញប្រើប្រាស់រួច
- រៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់គ្រប់គ្រងការលក់ដេញថ្លៃជាសាធារណៈចំពោះទ្រព្យបញ្ចាំដែលដល់កាលវសាន្ត និងរៀបចំវេទិកាដេញថ្លៃជាសាធារណៈ
- ពិនិត្យ និងផ្តល់អាជ្ញាបណ្ណជូនដល់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និង ទទួលប្រាតិភោគដោយអនុប្បទាន
- គ្រប់គ្រង និងប្រមូលថ្លៃសេវាផ្សេងៗដែលជាកាតព្វកិច្ចរបស់អាជីវកម្ម
- ចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងប្រកបអាជីវកម្មជាប្រចាំ ឬក្នុងករណីមានការសង្ស័យ ឬក្នុងករណីមានបណ្តឹង
- រៀបចំវគ្គបណ្តុះបណ្តាលសំរាប់ពង្រឹងសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈអ្នកកាន់អាជ្ញាបណ្ណ
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗ ទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ៣១.-**

ការិយាល័យស្រាវជ្រាវ និងបង្ក្រាបបទល្មើសអាជីវកម្ម មានភារកិច្ចដូចតទៅ÷

- ស្រាវជ្រាវ និងបង្ក្រាប ការធ្វើអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន សេវាកម្មវាយតម្លៃ សេវាកម្មអចលនទ្រព្យអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងប្រាតិភោគដោយអនុប្បទានដោយគ្មានអាជ្ញាបណ្ណអាជីវកម្មទិញ-លក់ទំនិញប្រើប្រាស់រួច
- ដាក់ទណ្ឌកម្មពិន័យរដ្ឋបាលចំពោះការអនុវត្តផ្ទុយទៅនឹងបញ្ញត្តិនានា ដែលក្រសួងបានកំណត់
- ចូលរួមតាមដានសកម្មភាពសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មអចលនវត្ថុ បញ្ចាំ ប្រាតិភោគដោយអនុប្បទាន និងអាជីវកម្មទិញ និងអាជីវកម្មទិញ-លក់ទំនិញប្រើប្រាស់រួច

- ចុះត្រួតពិនិត្យដល់ទីកន្លែងជាប្រចាំ ឬក្នុងករណីមានភាពមិនប្រក្រតី ឬក្នុងករណីមានបណ្តឹង
- ធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំនាយកដ្ឋានជ្រាប និងផ្តល់ការណែនាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗ ទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី៧
## លេខាធិការដ្ឋាន

**ប្រការ៣២.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដោយមានតួនាទី និងភារកិច្ចដូចតទៅ ÷

- ជាជំនួយការអគ្គនាយក និងអគ្គនាយករងសម្រាប់ប្រតិបត្តិការការងារប្រចាំថ្ងៃ
- គ្រប់គ្រង និងតាមដាន លិខិតចេញ-ចូល សារាចរ តំកល់ឯកសាររដ្ឋបាល និងបែងចែកឯកសារតាមមុខងារ និងភារកិច្ចរបស់នាយកដ្ឋាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ជាជំនួយការឱ្យអគ្គនាយក ក្នុងការតាមដានបញ្ហារបស់អគ្គនាយកលើការអនុវត្តកិច្ចការរបស់នាយកដ្ឋាននីមួយៗ ពិនិត្យខ្លឹមសារលិខិតផ្សេងៗ របស់នាយកដ្ឋាន
- ជំនួយរៀបចំ គ្រប់គ្រង និងអនុវត្តថវិកា ព្រមទាំងគ្រប់គ្រង ត្រួតពិនិត្យការផ្គត់ផ្គង់សន្និធិ សម្ភារៈ និងបើកផ្តល់សម្ភារៈបរិក្ខារការិយាល័យដល់នាយកដ្ឋាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- គ្រប់គ្រង និងត្រួតពិនិត្យ រាល់សន្និធិ សម្ភារៈ និងអនុម័តការស្នើសុំផ្គត់ផ្គង់សម្ភារៈបរិក្ខាររបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រង និងត្រួតពិនិត្យគេហទំព័ររបស់អគ្គនាយកដ្ឋាន
- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំនានាដែលស្ថិតក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- បំពេញតួនាទី និងភារកិច្ចផ្សេងៗ ទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ៣៣.-**

ក្នុងការបំពេញភារកិច្ច ការងារទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ច របស់អគ្គនាយកដ្ឋានជំនាញដទៃនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ រួមគ្នាដោះស្រាយ ឬសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការកំណត់ ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៣៤.-**

ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងប្រកាសលេខ ០៣១ សហវ.ប្រក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្តីពីការបង្កើតការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាននៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

បណ្ឌិត ... ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល</u> ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

